សុន្ទរកថារបស់ **ឯកឧត្តម គូម៉ាម៉ារូ យូជិ** ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព
របស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយ
សម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ របស់ប្រទេសជប៉ុន

២០ ធ្នូ ២០១៣

**សូមគោរព លោក ខាន់ ម៉ាណោរ ប្រធានមន្ទីរសាធារណៈការ និងដឹកជញ្ជូនខេត្តបាត់ដំបង!**
**សូមគោរព លោក វ៉ាន់ មុត ប្រធានក្រុមប្រឹក្សាឃុំកំពង់ស្រឡៅ១ ស្រុកឆែប ខេត្តព្រះវិហារ!**
**សូមគោរព អស់លោក លោកស្រី!**

ខ្ញុំមានសេចក្តីសោមនស្សរីករាយដើម្បីប្រារព្ធពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយចំនួន ២ សម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ។ ខ្ញុំក៏មានសេចក្តីសោមនស្សរីករាយជាពិសេសផងដែរ ដែលកិច្ចសន្យាផ្តល់ជំនួយទាំងនេះត្រូវបានធ្វើឡើងក្នុងឆ្នាំ២០១៣ដែលជាឆ្នាំខួបអនុស្សាវរីយ៍ទី៦០នៃទំនាក់ទំនងមិត្តភាពជប៉ុន-កម្ពុជា។

គម្រោងទីមួយមានថវិកាសរុប ១០៦,៤១៧ ដុល្លាអាមេរិក ផ្តល់ជូនមន្ទីរសាធារណៈការ និងដឹកជញ្ជូនខេត្តបាត់ដំបងដើម្បីសាងសង់ប្រព័ន្ធលូរំដោះទឹកប្រវែង១,០៧០ម៉ែត្រ តាមបណ្តោយផ្លូវជាតិលេខ៥ ចំណុចរង្វង់មូលព្រះនារាយណ៍ក្នុងក្រុងបាត់ដំបង។ យើងសង្ឃឹមថា គម្រោងនេះនឹងបង្កើនសមត្ថភាពគ្រប់គ្រងទឹកជំនន់ ព្រមទាំងកែលម្អបរិស្ថានឲ្យមានសុវត្ថិភាព និងអនាម័យសម្រាប់ប្រជាជនក្នុងតំបន់ប្រមាណ១៨,០០០នាក់ ។

គម្រោងទីពីរមានថវិកាសរុប ១០៧,៥៤៥ ដុល្លាអាមេរិក ផ្តល់ជូនក្រុមប្រឹក្សាឃុំកំពង់ស្រឡៅ១ ស្រុកឆែប ខេត្តព្រះវិហារដើម្បីសាងសង់កំពង់ផែថ្មីមួយនិងផែបណ្តែតទឹកចល័តមួយសម្រាប់ប្រើប្រាស់ក្នុងការធ្វើដំណើរឆ្លងទន្លេមេគង្គ។ យើងសង្ឃឹមថាគម្រោងនេះនឹងផ្តល់ផលប្រយោជន៍ដល់ប្រជាជនជាង៥,០០០នាក់ក្នុងតំបន់នោះដែលត្រូវការធ្វើដំណើរឆ្លងកាត់ទន្លេក្នុងគោលបំណងផ្សេងៗគ្នាជាច្រើន។ យើងក៏រំពឹងផងដែរថាកំពង់ផែថ្មីនេះនឹងរួមចំណែកលើកស្ទួយសេដ្ឋកិច្ចក្នុងតំបន់តាមរយៈការបង្កើនពាណិជ្ជកម្មជាមួយប្រទេសឡាវ។

ការគ្រប់គ្រងទឹកជំនន់ និង ការដឹកជញ្ជូនតាមទន្លេនៃគម្រោងទាំងពីរនេះ គឺជាវិស័យដ៏មានសារៈសំខាន់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ចរបស់កម្ពុជា ហើយរាជរដ្ឋាភិបាលកម្ពុជាក៏បាន និង កំពុងបន្តខិតខំប្រឹងប្រែងកែលម្អវិស័យទាំងពីរនេះផងដែរ។

ដោយទទួលស្គាល់អំពីសារៈសំខាន់នៃវិស័យទាំងពីរនេះរដ្ឋាភិបាលជប៉ុនបាន និងកំពុងបន្តផ្តល់ការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាតាមរយៈការសាងសង់ប្រព័ន្ធលូរំដោះទឹក និង សាងសង់សំណង់កំពង់ផែជាដើម។

ខ្ញុំសង្ឃឹមថាគម្រោងទាំងពីរនេះនឹងត្រូវបានអនុវត្តយ៉ាងរលូន និងប្រកបដោយប្រសិទ្ធភាពដោយដៃគូរបស់យើងគឺមន្ទីរសាធារណៈការ និងដឹកជញ្ជូនខេត្តបាត់ដំបង និងក្រុមប្រឹក្សាឃុំកំពង់ស្រឡៅ១ ហើយនឹងត្រូវបានថែទាំយ៉ាងត្រឹមត្រូវដើម្បីប្រជាជនកាន់តែច្រើនអាចទទួលបានអត្ថប្រយោជន៍ពីគម្រោងទាំងនេះ។

ជាចុងក្រោយនេះ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថាគម្រោងនេះនឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពដែលមានស្រាប់រវាងប្រជាជនជប៉ុន និង ប្រជាជនកម្ពុជា។ សូមអរគុណ!